This project is co-funded by:

**F2F group 3 formation workshop report:**

The workshop was organized in from 2-3 Aug 2011 in one of our CNFSC member office in Koh Kong province. The purpose of the workshop is to share the concept of Farmer to Farmer Exchange Initiative and forming the model farmers group 3 to take up this initiative. There are five CNFSC members joined in this group 3, KAFDOC, KIPD, KDDF, CWDCC and KABB,

# កំណត់ហេតុ

ចងក្រងកសិករគំរូក្រុមទី៣

ឆ្នាំពីរពាន់ដប់មួយ ខែសីហា ថ្ងៃទីពីរ វេលាម៉ោងប្រាំព្រឹកនៅការិយាល័យអង្គការមជ្ឈមណ្ឌលម្លប់ព្រហ្មវិហារធម៌ ស្រុកស្រែអំបិល ខេត្តកោះកុង មានការប្រជុំមួយរបស់ក្រុមស្នូលបណ្ដាញសហគមន៍ដើម្បីអធិបតេយ្យភាពស្បៀងនៅកម្ពុជា ដើម្បីចងក្រងកសិករគំរូក្រុមទី៣ ក្រោមការសំរបសំរួលរបស់លោក ជឹម សុផលប្រធានបណ្ដាញសហគមន៍ដើម្បីអធិបតេយ្យភាពស្បៀងនៅកម្ពុជា ។

ក្រោយពីជួបជុំគ្នា អ្នកស្រី ស៊ិន ស៊ីណនបានជំរាបពីកម្មវិធីប្រជុំរយៈពេល២ថ្ងៃដល់សិក្ខាកាមទាំងអស់គ្នាដូចបានចែកជូន ។

បន្ទាប់មតិស្វាគមន៍ លោក ម៉េង ហាក់វិជ្ជ័យ នាយកប្រតិបត្តិអង្គការមជ្ឈមណ្ឌលម្លប់ព្រហ្មវិហារធម៌: ជាបឋម ខ្ញុំសូមស្វាគមន៍ចំពោះការមកដល់ និងជ្រើសរើសទីនេះសំរាប់ប្រជុំរៀបចំកសិករគំរូក្រុមទី៣ នេះ ។ម្យ៉ាងទៀត យើងបានជួបជុំគ្នា អាចមានពេលវេលាជួបជជែកគ្នា និងមានភាពស្និទ្ធស្នាលចំពោះគ្នានិងគ្នាផងដែរ ។ ក្នុងនេះដែរ ខ្ញុំសង្ឃឹមថា អស់លោក លោកស្រី នឹងមានការអធ្យាស្រ័យរាល់ការណាដែលមិនគាប់ប្រសើរ ចំពោះទីកន្លែង និងការសំរាកនៅទីនេះ ។ ចុងក្រោយនេះ ខ្ញុំសូមជូនពរដល់អស់លោក លោកស្រីជួបនូវសុភមង្គល និងជោគជ័យក្នុងការរៀបចំក្រុមកសិករក្រុមទី៣ នេះ។

មតិបើកកម្មវិធីប្រជុំលោក ជឹម សុផលប្រធានបណ្ដាញសហគមន៍ដើម្បីអធិបតេយ្យភាពស្បៀងនៅកម្ពុជា: នេះជាលើកទី៣ ហើយដែលក្រុមស្នូលសន្តិសុខស្បៀងយើងបានរៀបចំក្រុមកសិករគំរូ ។ កន្លងមកយើងមានក្រុមទី១ដូចជា: ខេត្តព្រះវិហារ សៀមរាប កំពង់ធំ និងខេត្តព្រៃវែង ឯក្រុមទី២មាន៤ខេត្តគឺ កំពង់ចាម ពោធិសាត់ ស្វាយរៀង និងស្រុកស្រែអំបិល ចំណែកថ្ងៃនេះយើងបានរៀបចំក្រុមទី៣មានចំនួន៥ខេត្ត: បាត់ដំបង កំពង់ស្ពឺ ព្រះវិហារ(ស្រុកជាំក្សាន) ក្រចេះ និងខេត្តកំពត ។ គោលបំណងដើម្បីអោយកសិករតាមខេត្តនីមួយៗចេះចែករំលែកជំនាញកសិកម្ម ការប្រើប្រាស់ដី និងធនធានអោយអស់លទ្ធភាព និងពង្រីងបច្ចេកទេសដល់ពួកគាត់ ។ ខ្ញុំសង្ឃឹមថា រយៈពេល២ថ្ងៃនេះ យើងនឹងទទួលបានលទ្ធផលតាមដែលយើងគ្រោងគឺទី១ – ចងក្រងក្រុម ២– មានផែនទីបច្ចុប្បន្ន និងផែនទីក្ដីស្រមៃ ហើយទី៣ – រៀបចំផែនការអនុវត្តន៍នៅពេលត្រឡប់ទៅវិញ ។

ជាចុងក្រោយ ខ្ញុំសុំណូមពរអោយអស់លោកយកចិត្តទុកដាក់ចំពោះការប្រជុំនេះ ដើម្បីសំរេចគោលបំណង ។ ដូចនេះខ្ញុំ សូមប្រកាសបើកកម្មវិធីប្រជុំពីពេលនេះតទៅ ដោយស្របតាមរបៀបវារៈ និងកម្មវិធីដែលបានគ្រោងទុក ។

ក្រោយពីមតិសំណេះសំណាល និងបើកម្មវិធីប្រជុំរបស់ប្រធានបណ្តាញរួចហើយ  អ្នកស្រី ស៊ិន ស៊ីណេនបានលើកបង្ហាញពីគោលគំនិត និងគោលបំណងនៃការចងក្រងកសិករគំរូក្រុមទីបីដូចខាងក្រោម៖

**សេចក្តីផ្តើម**

ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលពឹងអាស្រ័យលើផលកសិកម្ម ដោយប្រជាជនច្រើនជាង៨០ %រស់នៅ និងពឹងអាស្រ័យលើផ្នែក កសិកម្មនេះ។ នៅតំបន់ជនបទ ស្ថានភាពរបស់ប្រជាជនត្រូវបានចែងចែកជាបួនប្រភេទគឺ ក្រីក្របំផុត ក្រីក្រ ក្រោមមធ្យម និង មធ្យម។ គ្រួសារក្រីក្របំផុត និងក្រីក្រដែលមានដីតិចតួចគឺអាចប្រកបមុខរបរកសិកម្មតិចតួច ឬក៏មិនធ្វើអ្វីសោះនៅលើដីនោះ។ គ្រួសារក្រីក្របំផុត និងគ្រួសារដែលក្រីក្រ ក៏ពឹងអាស្រ័យលើការចិញ្ចឹមក្នុងស្រុកមួយចំនួនផងដែរដូចជា ជ្រូក មាន់ទា ជាដើម។ ពួកគាត់តែងតែជួបនូវកង្វះស្បៀងពី៣ខែ ទៅ៦ខែក្នុងមួយឆ្នាំ។

ក្នុងរយៈពេល២ឆ្នាំកន្លងមកនេះ បណ្តាញសហគមន៍ដើម្បីអធិបតេយ្យភាពស្បៀងនៅកម្ពុជាបានបង្កើតឡើងដើម្បីបង្កើតឱកាសឱ្យ សហគមន៍រៀបចំចងក្រង និងប្រមូលផ្តុំសហគមន៍ទូទាំងប្រទេសដើម្បីប្រយុទ្ធប្រឆាំង ដើម្បីសិទ្ធិរបស់ពួក គេក្នុងការទទួលបានជីវភាព ប្រកបដោយសេចក្តីថ្លៃថ្នូរ។ និយាយអំពីការងារដែលពាក់ព័ន្ធនឹងសិទ្ធិទទួលបានចំណីអាហារ បណ្តាញក៏ពង់តែផ្តោតទៅលើការពង្រឹង អង្គការ និងសម្ព័ន្ធរបស់ប្រជាជនក្រីក្រ និងរងគ្រោះ ដោយមានការចូលរួមស្មើគ្នា នៃក្រុមដែលសង្គមផាត់ចោល ជាពិសេសស្ត្រីក្នុងការ ធ្វើការរួមគ្នាដើម្បីទាមទារ និងប្រើប្រាស់សិទ្ធិរបស់ពួកគាត់ក៏ដូចជាពង្រឹង គោលនយោបាយគាំពារអ្នកក្រីក្រ ដើម្បីសហគមន៍ក្រីក្រ និងសង្គមផាត់ចោលទាំងនោះទាមទារ និងទទួលបាននូវសិទ្ធិរបស់ខ្លួនពេញលេញ។

<u>គោលបំណងនៃការរៀបចំក្រុមកសិករ</u>

ការរៀបចំក្រុមកសិករគំរូគឺជាកម្មវិធីផ្តួចផ្តើមថ្មីដែលកើតឡើងដោយបណ្តាញសហគមន៍ដើម្បីអធិបតេយ្យភាពស្បៀងនៅកម្ពុជា ដែលជាអ្នកដើរតួយ៉ាងសំខាន់ក្នុងការចងក្រង និងប្រមូលផ្តុំសហគមន៍ដើម្បីសិទ្ធិទទួលបានចំណីអាហាររបស់ពួកគាត់។ ក្នុងរយៈពេល២ឆ្នាំនេះ បណ្តាញបានផ្តោត និងអនុវត្តន៍ការងារជាច្រើនលើការតស៊ូមតិ និងយុទ្ធនាការជុំវិញបញ្ហាដីធ្លី នេសាទ និងធនធានធម្មជាតិ នានា។ រហូតដល់ឆ្នាំ២០០៩នេះ ក្រុមការងារបានគិត និងសំរេចចិត្តផ្តួចផ្តើមការងារលើផ្នែកកសិកម្ម ដោយដំបូងផ្តោតលើការពង្រឹង ចំណេះដឹងក្នុងស្រុកលើផ្នែកកសិកម្មដល់កសិករក្នុងស្រុកតាមរយៈការអនុវត្តន៍ផ្ទាល់ ការចែករំលែកការរៀនសូត្រ និងការឆ្លុះបញ្ចាំង ជាមួយកសិករផ្សេងៗទៀតនៅជុំវិញប្រទេស។ គោលបំណងចំបងនៃកម្មវិធីផ្តួចផ្តើមនេះគឺ៖

- ដើម្បីចងក្រងកសិករគំរូមួយចំនួននៅក្នុងតំបន់ដៃគូដែលបានជ្រើសរើស និងពង្រឹងចំណេះដឹងរបស់ពួកគាត់លើផ្នែកកសិកម្ម ដើម្បីអនុវត្តន៍លើដីថ្មីរបស់ពួកគាត់ ព្រមទាំងផ្សព្វផ្សាយចំណេះដឹងទាំងនោះដល់កសិករដទៃទៀត។
- ដើម្បីពង្រឹងជំនាញរបស់កសិករក្នុងស្រុកលើផ្នែកកសិកម្ម ជាពិសេសពង្រឹងសមត្ថភាព និងចំណេះដឹងកសិករលើការប្រើប្រាស់ដីរបស់ពួកគាត់អោយអស់លទ្ធភាព តាមរយៈបច្ចេកទេសកសិកម្មសរីរាង្គក្នុងស្រុកដែលមានតំលៃថោក និងសមស្រប។
- ដើម្បីផ្តួចផ្តើមអោយមានកសិដ្ឋានបង្ហាញ និងកសិដ្ឋានគំរូដើម្បីផ្សព្វផ្សាយជំនាញ ឬចំណេះដឹង និងការយល់ដឹងទៅកសិករផ្សេងៗទៀត។

- ដើម្បីរៀបចំអោយមានគ្រូបង្គោលផ្នែកកសិកម្មក្នុងភូមិ ដែលអាចចែករំលែក និងបង្ហាញដល់កសិករដទៃទៀត។

<u>លក្ខណៈសម្បត្តិនៃក្រុមកសិករគំរូ:</u>

- ជាកសិករក្រីក្រ និងដែលបានអនុវត្តន៍ល្អនៅតាមភូមិគោលដៅរបស់សមាជិកបណ្តាញ
- មានចិត្ត និងស្វាហាប់ក្នុងការអនុវត្តន៍ការងារកសិម្ម
- មានចិត្ត និងយកចិត្តទុកដាក់ក្នុងការចែករំលែក និងបង្រៀនទៅដល់កសិករដទៃ
- ប្រែក្លាយដីកសិកម្មរបស់ខ្លួនទៅជាសួនបង្ហាញ
- មានស្មារតីចែករំលែក និងផ្លាស់ប្តូរបទពិសោធន៍ ចំណេះដឹង ធនធាននៅក្នុងសហគមន៍ និងនៅក្នុងបណ្តាញ។





បន្ទាប់មកយើងបានធ្វើការណែនាំអោស្គាល់គ្នាពី ឈ្មោះ និងតួនាទី មកពីខេត្តណា ស្រុកណា ឃុំណា ភូមិណា ធ្លាប់ដាំអ្វីខ្លះ? និង មកពីអង្គការណា ? ដោយចាប់ដៃគូពីរៗនាក់មកពីខេត្តផ្សេងៗគ្នា និងមានលទ្ធផលពិភាក្សាដូចខាងក្រោម:

ការចូលរួមរបស់បុគ្គលិកដឹកនាំកសិករ:

- ប៉ុល ស៊ីនួន មកពីអង្គការKABB : ចំពោះកសិករឃើញថា ពួកគាត់ធ្លាប់បានដាំរួចមកហើយ តែចំណុចដែលគួអោយចាប់អារម្មណ៍និងកែលំអរគឺ ពួកគាត់ ដំាដុះ និងចិញ្ចឹមតាមទំលាប់ ហើយប្រើប្រាស់ជីគីមីច្រើន និងប្រើប្រាស់ដីមិនទាន់អស់លទ្ធភាព។ ដូច្នេះ ខ្ញុំសំណូមពរ អោយមានការបណ្តុះបណ្តាលបច្ចេកទេសដល់ពួកគាត់ និងរកវិធីជួយអោយគាត់បានយល់ពីសារៈសំខាន់នៃការជីធម្មជាតិ ។
- លោក ដែង សារឿត មកពីអង្គការKAFDOC :យល់ថា នេះជាវគ្គសំខាន់បំផុត និងជាឱកាសសំរាប់កសិករក្រីក្ររបស់យើង ។ យ៉ាងនេះធ្វើអោយគាត់ បានចែករំលែកបទពិសោធន៍ និងជំនាញពីកសិករម្នាក់ទៅម្នាក់ទៀត ពីតំបន់មួយទៅតំបន់មួយ ជាពិសេសបានអនុវត្តផ្ទាល់ មិនត្រឹមតែរៀនតែទ្រឹស្តីនោះទេ ។ ខ្ញុំសង្ឃឹមថា យើងនឹងបានទទួលចំណេះដឹងថ្មីៗ និងយកទៅអនុវត្តន៍បានល្អនៅមូលដ្ឋានរបស់ខ្លួន ។

- លោក ណម ពារមកពីអង្គការKIPD : ខ្ញុំសង្ឃឹមថា កសិករយើងទទួលបានជំនាញច្រើនពីក្រុមការងារ ចំពោះការប្រជុំនេះ ហើយខ្ញុំនឹងព្យាយាមជួយជំរុញ ដឹកនាំពួកគាត់អោយទទួលបានជោគជ័យ ។
- លោក ពុំ លីមកពីអង្គការCWDCC: ខ្ញុំមានការចាប់អារម្មណ៍ច្រើន ហើយកសិករក៏មានចំណាប់អារម្មណ៍ច្រើន ជាពិសេសការធ្វើជីធម្មជាតិ កំប៉ុសគោក–ទឹក តែសូមអោយពង្រឹងសមត្ថភាពបន្ថែម លើបច្ចេកទេសដាំដុះជាដើម ។ ខ្ញុំសំរេចចិត្តនឹងជំរុញអោយមានការរីកចំរើនបន្ថែមទៀត ។
- លោក ស៊ិន វាសនា មកពីអង្គការKDDF: គឺយើងរកអ្នកណាដែលស្មគ្រ័ចិត្តធ្វើ ហើយពង្រឹងសមត្ថភាពគាត់ថែមទៀត លើការដាំដុះ ចិញ្ចឹមសត្វ និងធ្វើស្រែចំការ ជាពិសេសយើងចង់អោយបង្កើនលើការប្រើប្រាស់ជីធម្មជាតិ ។

លទ្ធផលពិភាក្សា/ព័ត៌មានសមាជិកកសិករ (តារាង)

**កសិករគំរូក្រុមទី៣ មាន៥អង្គការ បង្កើតនៅ ថ្ងៃទី២-៣ ខែសីហា ឆ្នាំ២០១១ នៅស្រុកស្រែអំបិល**

| ល.រ | ឈ្មោះកសិករ | ភេទ | អង្គការ | ស្ថានភាពគ្រួ. | ភូមិ | ឃុំ | ស្រុក | ខេត្ត | ទំហំដី | ដាំអ្វីខ្លះ |
|---|---|---|---|---|---|---|---|---|---|---|
| ណម ពារ | | ប | KIPD | **បុគ្គលិកដឹកនាំកសិករ** | | | | | | |
| 1 | ស៊ឹម ទុង | ប | KIPD | កូន៣ ស្រី២ | វាលពោធិ៍ | ជាំក្សាន្ត | ជាំក្សាន | ព្រះវិហារ | ១ហ | ថ្មើស្រែ |
| 2 | វ៉ៃ ហុង | ប | KIPD | កូន៤ស្រី | គោក | រំដោះស្រែ | ជាំក្សាន | ព្រះវិហារ | ២ហ | ធ្វើស្រែ, ស្លឹកគ្រៃ,រំដេង,ត្រឡាច |
| 3 | វិត អេត | ស | KIPD | កូន១ ប្រុស | ស្វាយ | រំដោះស្រែ | ជាំក្សាន | ព្រះវិហារ | ៤0គុ៧0 | ននោង, ជ្រូក, មាន់, ស្វាយ |
| 4 | ប៉ាល់ យឿន | ប | KIPD | កូន៦ប្រុស២ | ត្រពាំងធំ | ទឹកក្រហម | ជាំក្សាន | ព្រះវិហារ | | ស្ពៃខៀវ, ននោង, ម្ទេស, ផ្សិតអំបោះ |
| ដែង សារឿត | | ប | KAFDOC | **បុគ្គលិកដឹកនាំកសិករ** | | | | | | |
| 5 | សួង សុភាព | ប | KAFDOC | កូន២ស្រី១ | កំពង់គរ | ជ្រោយស្នែងក្របីក្រោម | ព្រែកប្រសព្វ | ក្រចេះ | | ដាំបន្លែ, ខ្ទឹម, ត្រកួន, ស្ពៃចង្កឹះ, ជ្រូក |
| 6 | អ៊ិន អ៊ីន | ប | KAFDOC | កូន១ ស្រី | ជ្រោយបន្ទាយ | ខ្សាច់ទុប | ព្រែកប្រសព | ក្រចេះ | ១ហ | ដំឡូងមី, ស្រូវ, |
| 7 | ប៉ុល ទ្រី | ប | KAFDOC | កូន១១ប្រុស៨ | ឫស្សីកែវ | ស្វាយជុំ | ព្រែកប្រសព | ក្រចេះ | ១២គុ៦៥ | ស្ពៃ, ម្រះ, ត្រកួន, ត្រប់, ដំឡូងជ្វា |
| 8 | ឌុក សុនីន | ស | KAFDOC | កូន៣ស្រី២ | ជ្រោយបន្ទាយ | កែង | ព្រែកប្រសព | ក្រចេះ | ២ហ | ដំឡូងមី, ពោតក្រហម, ស្រូវ, មាន់, |
| ពុំ លី | | ប | CWDCC | **បុគ្គលិកដឹកនាំកសិករ** | | | | | | |
| 9 | ឈិត ហូ | ប | CWDCC | ២យាយតា | ត្រពាំងសង្កែ | ត្រពាំងសង្កែ | ទឹកឈូរ | កំពត | | ដំឡូងមី,ត្រាវ,ជីរណា,ខ្ទឹម,អំពៅ,ននោង,ពពាយ,ស្លឹកគ្រៃ,រំដេង |
| 10 | កែវ គង់នៅ | ប | CWDCC | កូន៣ស្រី១ | ត្រពាំងស្ដៅ | ត្រពាំងភាំង | ឈូក | កំពត | ២ហ | ស្វាយ មាន់ បន្លែរមផ្សំ, ជីប៉ុស |
| 11 | ទុយ ស្រីមួយ | ស | CWDCC | មានប្ដី | ជ័យសេនា | តាកែន | ឈូក | កំពត | | ននោង,ជី,ខ្ទឹម,មាន់,ជ្រូក,បន្លែ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 12 | ង៉ែត សុផន | ស | CWDCC | កូន៤ស្រី២ | កោះស្វា | ត្រពាំងភ្លាំង | ឈូក | កំពត | ១៥០គុ៣០ | ពពាយ,ខ្ទឹម, គ្រប់,ជីរណា,ស្លឹកគ្រៃ,សណ្តែកគួរ, ពោត,ល្ពៅ,រមៀត,រំដេង |
| ប៉ុល ស៊ីនួន | | ប | **បុគ្គលិកដឹកនាំកសិករ** | | | | | | | |
| 13 | ឈើ រិត | ប | KABB | កូន១ | បឹងសង្កែ | ក្តុលតាហែន | បវិល | បាត់ដំបង | ៤០គុ៦០ | ស្ពៃចង្កឹះ, សណ្តែកគួរ, ស្រៃ,ត្រសក់ |
| 14 | សាន់ សាវី | ប | KABB | កូន៦ ប្រុស២ | អន្លង់វាំង | ក្តុលតាហែន | បវិល | បាត់ដំបង | | ជីគ្រប់,រមៀត,ចេក,ក្រូច,ស្វាយ,ខ្នុរ,ប្រសកានាគ, ត្រឡាច, ននោង,ស្រះត្រី |
| 15 | ម៉ឺន នាង | ស | KABB | កូន៦ ស្រី២ | ទួលស្នួល | ក្តុលតាហែន | បវិល | បាត់ដំបង | | ត្រសក់, សណ្តែកគួរ, ដំឡូងគរ,មាន់ទា |
| 16 | អ៊ិត គីមណា | ស | KABB | កូន៣ ស្រី១ | ឃ្លាំង | ក្តុលតាហែន | បវិល | បាត់ដំបង | | ស្លឹកគ្រៃ, ស្ពៃចង្កឹះ,ត្រសក់,ខ្ទឹម,ខ្វាយ... |
| ស៊ិន វាសនា | | ប | KDDF | **បុគ្គលិកដឹកនាំកសិករ** | | | | | | |
| 17 | សឿន រិទ្ធី | ប | KDDF | កូន២ប្រុស | អូរពង្រ | ស្រង់ | គងពិសី | កំពង់ស្ពឺ | | ខាត់ណាផ្កា,ប៉េងប៉ោះ,សណ្តែកបាយ |
| 18 | អ៊ុំង ធុំ | ប | KDDF | កូន១ | ស្វាយ | ស្រង់ | គងពិសី | កំពង់ស្ពឺ | | ដំឡូងមី,ស្រូវបវស,ននោង,ស្លឹកគ្រៃ,ប៉េងប៉ោះ,ជីកស្រះ |
| 19 | ឡុង ជ្រាប | ស | KDDF | កូន១ ប្រុស | អូរពង្រ | ស្រង់ | គងពិសី | កំពង់ស្ពឺ | | ត្រសក់ ត្រឡាច ស្លឹកគ្រៃ ល្ពៅ សណ្តែក ត្រកួន ស្ពៃចង្កឹះក្រញាញ់ខ្មៅ |
| 20 | ឯក រ៉ម | ស | KDDF | លីវ | អូរតាវ៉ាន | ស្រង់ | គងពិសី | កំពង់ស្ពឺ | | ត្រសក់ ល្ហុង ស្វាយ |

ការចែករំលែកពីយុទ្ធសាស្ត្រលើកស្ទួយសហគមន៍ (ស៊ិន ស៊ីណន)




សំរាកអាហារសំរន់:

**ល្បែងបកចេក:**សំរបសំរួលដោយ លោក ជីម សុផល(សិក្ខាកាមឈរជារង្វង់មូល រួចធ្វើកាយវិការបកចេកតាមអ្នកសំរបសំរួល) ។



បន្ទាប់មកលោក អូត ឡុង និងលោក សុខ រឿនធ្វើការបង្ហាញបទពិសោធន៍របស់កសិករក្រុមទី១ :

- លោក អូត ឡុង: ពីមុនមកលោក សង្ឃឹមថា ទទួលបានគាំទ្រសំភារ:ពីអង្គការ តែផ្ទុយទៅវិញប្រៀបដូចក្មេងលេងបាយឡុអញ្ចឹង ព្រោះថា នៅពេលដែលយើងចូលរួមសិក្ខាសាលា គេតំរូវអោយយើងគូផែនទី (ទីផ្ទះបច្ចុប្បន្ន និងផែនទីក្តីស្រម៉ៃ) ធ្វើផែនការសំរាប់អនុវត្តក្រោយពេលសិក្ខាសាលា។ ដូច្នេះ រហូតមកដល់ពេលនេះ យើងមានកសិករគំរូ៣ក្រុមរួមទាំងក្រុម

ទី៣ នេះ ។ បន្ទាប់ពីការចងក្រងនេះ យើងនឹងធ្វើការបណ្តុះបណ្តាលដល់ក្រុមទី៣ នៅខេត្តព្រះវិហារ ស្រុករវៀង ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ ដល់ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១។

- លោក សុខ រឿន៖ (ប្រហាក់ប្រហែលលោក អួត ឡុង)គំនិតនៃការបង្កើតកសិករគំរូនេះគឺក្រុមស្នូលសន្តិសុខស្បៀង គឺធ្វើយ៉ាងណា យើងជាកសិករគំរូ ពេលទៅវិញត្រូវរៀបចំផែនការ រៀបចំស្នូន និងអនុវត្តន៍អោយជោជ័យ ទើបយើងធ្វើការពង្រីកកសិករអោយបាន៥នាក់ និងចែករំលែកចំណេះដឹងដែលយើងមានទៅសមាជិករបស់យើង។ ម្យ៉ាងទៀត យើងត្រូវធ្វើការប្រជុំចែករំលែកបទពិសោធន៍ និងចំណេះដឹងដែលយើងបានទទួលការបណ្តុះបណ្តាលពីអង្គការ និងសិក្ខាសាលាផ្សេងៗ។

បន្ទាប់មកអ្នកសំរបសំរួលបានធ្វើការបង្ហាញពីរបៀបគូផែនទីដែលបញ្ជាក់ទីផ្ទះពិតប្រាកដ និងដំណាំ ជាពិសេសធនធានដែលមាននៅជុំវិញផ្ទះ ។ ការគូផែនទីគឺបែងចែកទៅតាមសមុីកសិករម្នាក់ៗ និងសំរបសំរួលដោយបុគ្គលិកអង្គការទទួលបន្ទុក។ ជាលទ្ធផលកសិករម្នាក់ៗទទួលបានផែនទីគ្រប់គ្នា ។

**សកម្មភាពគូផែនទីជាក់ស្តែង៖**





**សកម្មភាពគូផែនទីក្តីស្រមៃ**






ក្រោយពីសិក្ខាកាមទាំងអស់បានគូផែនទីក្តីបច្ចុប្បន្ន និងផែនទីក្តីស្រម៉ៃរួចរាល់ ពួកគាត់បានធ្វើការបង្ហាញដល់ក្រុមធំតាមសមាជិកម្នាក់ ដើម្បីអោយក្រុមធំ និងក្រុមស្នូលកសិករបានយល់ និងជួយផ្តល់យោបល់កែលំអរ គោលបំណងងាយស្រួលរៀបចំផែនការសំរាប់អនុវត្តន៍នៅពេលត្រឡប់ទៅវិញ ។

**មតិក្រុមធំ និងក្រុមស្នូលៈ**

- បុគ្គលិកដឹកនាំកសិករគួរផ្តល់យោបល់លើផែនទី និងផែនការអនុវត្តន៍នៅពេលត្រឡប់ទៅវិញ ។
- ស្រះចិញ្ចឹមត្រី មិនគួរធ្វើពីបេតុងទេ អាចនាំអោយខូចត្រី (លោក កែង គងនៅ ខេត្តកំពត) គួរធ្វើ ស្រះផ្លាស្ទិក
- អនាម័យទឹកសំរាប់ផឹក (ការពារជម្ងឺផ្សេងៗ)
- ទ្រុងមាន់មិនគួរដាក់នៅក្បែរផ្ទះបាយឡើយ (ប៉ះពាល់ដល់អនាម័យ)
- ដាំដំណាំគួរនៅក្បែរប្រភពទឹក
- នៅរដូវប្រាំងគួរដាំដំណាំណាដែលមិនសូវត្រូវការទឹក (នឹងបង្ហាញជូននៅពេលបើកវគ្គបណ្តុះបណ្តាលនៅកំពង់ធំ)
- បើយើងមានដើមឈើដូចជាដើមស្វាយ យើងគួរដាំជីរណានៅខាងក្រោម ព្រោះវាមិនត្រូវការពន្លឺច្រើន
- ត្រីអាចចិញ្ចឹមចាប់ពីខែមករា
- សុភាព គួរគូម្តងទៀត សំរាប់អោយបុគ្គលិកអ៊ុតសំរាប់ក្រុមតាមដាន និងខ្លួនឯង ។
- ជារួមក្រុមសំរបសំរួល ជួយផ្តល់យោបល់ និងកែសំរួលគឺគួរធ្វើយ៉ាងណាតាមជំហាន។ (គឺជំហានគីង្គក់)
- ចំពោះផែនទីគូធ្វើយ៉ាងណាអោយច្បាស់លាស់ ពិត និងជាក់ស្តែង
- បុគ្គលិកត្រូវត្រួតពិនិត្យ និងតាមដានការអនុវត្តការប្រើប្រាស់ដីតាមផែនការរបស់គាត់ ។

**សកម្មភាពបង្ហាញផែនទីក្តីស្រម៉ៃៈ (រូបភាព)**






បែងចែកក្រុមពិភាក្សាជា៤ក្រុម ដើម្បីចែករំលែកបទពិសោធន៍ការងារកសិកម្មកន្លងមកៈ

**ក្រុមទី១ៈ សឿន រិទ្ធី, សួង សុភាព, រីវ ហុង, អិត គឹមណា**

| លរ | សកម្មភាព | លទ្ធផល | បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|---|---|---|
| ១ | ដាំស្ពៃ | ១៨រង | ទាគូ | |

| | | | | |
|---|---|---|---|---|
| ២ | សណ្តែកគួរ | ៩រង | ចៃ រូញស្លឹក | បុកស្លឹកស្តៅ |
| ៣ | ល្ពៅ | ១០០គុម្ព | រលួយផ្លែ | |
| ៤ | ត្រសក់ | ១២រង | រួញដៃ | |
| ៥ | ម្ទេស | ១៥០០ដើម | រួញត្រួយ | កាត់ត្រួយចោល |
| ៦ | ត្រប់ | ៣០០ដើម | រលួយផ្លែ | |
| ៧ | ចិញ្ចឹមមាន់ | ១៤៧ក្បាល | រាកស ព្រូន ឈឺភ្នែក | |
| ៨ | ទា | ២៤ក្បាល | ទន់ជើង | បុកខ្ទឹម និងធ្យូងលាយចំណី |
| ៩ | ជ្រូក | ២ក្បាល | រាក ព្រូន គ្រុន | |
| ១០ | គោ | ១៧ក្បាល | អុតក្តាម សាទឹក | |

**ក្រុមទី២: ទុយ ស្រីមួយ, ស៊ឹម ទុង, អ៊ុង ឆុំ, អិន អ៊ុន, ឈិត ហួ**

| ល.រ | សកម្មភាព | លទ្ធផល | បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|---|---|---|
| ១ | មាន់ | ៦៦ក្បាល | ងាប់ ជំងឺ?? | |
| ២ | ត្រកួន | ៦ រង | រួញស្លឹក | |
| ៣ | ដំឡូងមី | ៥៥រង | | |
| ៤ | ប៉េងប៉ោះ | ៥រង | ដាំទឹក | |
| ៥ | ជីនាងវង និងខ្ទឹម | ២រង | | |
| ៦ | ជីរណា ត្រប់ | ២រង | | |
| ៧ | អំពៅ | ៥រង | | |
| ៨ | ត្រាវ | ៤រង | | |
| ៩ | ស្លឹកគ្រៃ | ៤៧គុម្ព | | |
| ១០ | ចេក | ២៨គុម្ព | ក្រាស៊ី | |
| ១១ | ជ្រូក | ២ក្បាល | ឈឺងាប់ | |
| ១២ | ទ្រុង មាន់ | ៥ទ្រុង | | |
| ១៣ | ស្រះទឹក | ៥ស្រះ | | |

**ក្រុមទី៣: ឯក រ៉ម, ប៉ុល ទ្រី, ឡុង ជ្រាប , សាន់ សារី**

| ល.រ | សកម្មភាព | លទ្ធផល | បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|---|---|---|
| ១ | ត្រកួន | ១២ រង | ចៃស លើសស្លឹក | បាចផេះ |
| ២ | ត្រសក់ | ១៥ រង | ស្លោក រញុម ស្លឹក | បំប៉នជីធម្មជាតិ និងទឹកគ្រប់ |
| ៣ | ត្រឡាច និងស្ពៃ | ២៥ គុម្ព | រួញស្លឹក ទងរលួយ | ប្រើថ្នាំធម្មជាតិ: ថ្នាំជក់ ស្លឹកទៀប ស្តៅ |

| | | | | |
|---|---|---|---|---|
| ៤ | ម្រេះ | ៣ ទ្រើង | ស្រាំ អុច ផ្លែក្រិន | ស្រោបក្រដាស ឬក្រណាត |
| ៥ | សណ្តែកទ្រើង | ១៥រង | ចៃដញ្ជក់ | ផ្សំថ្នាំធម្មជាតិសំបកស្លែង ស្តៅ បណ្តូលពេជ្រ ថ្នាំជក់, ទឹកនោម |
| ៦ | ដំឡូង | ៣០គុម្ព | ចៃរំដើម កណ្តៀស៊ី | បាញ់ថ្នាំ និងដាក់ថ្នាំ |
| ៧ | មាន់ | ១២០ក្បាល | ប៉ោងភ្នែក ដង្កោកាច់ | បន្តក់ថ្នាំ ចាក់វ៉ាក់សាំង ការពារ |
| ៨ | ជ្រូក | ២ក្ប មេ១ | អុតក្តាម, ប្រកាច់ | ចាក់វ៉ាក់សាំង |

**ក្រុមទី៤: ឈី វិត, ឌុក សុនីន, វិត ផេត, ប៉ាល់ យឿន, ង៉ែត សុផន**

| ល.រ | សកម្មភាព | លទ្ធផល | បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|---|---|---|
| ១ | ស្ពៃចង្កឹះ | ៧រង | | |
| ២ | សណ្តែកគួរ | ៣ រង | ចៃរុំ | ថ្នាំធម្មជាតិ |
| ៣ | ត្រកួន | ៥០ រង | | |
| ៤ | ផ្សិតអំបោះ | ១១០កញ្ចប់ | ផ្សិតក្លាយ | ដកចោល |
| ៥ | ដំឡូងមី | ២ហិកតា | កណ្តៀ រស៊ី | ប្រើថ្នាំគីមី |
| ៦ | មាន់ | ១២៨ក្បាល | ជំងឺ??? | |
| ៧ | ទា | ៦៩ក្បាល | ជំងឺ??? | |
| ៨ | ជ្រូក | ៤ក្បាល | ជំងឺ??? | |
| ៩ | គោ | ២ក្បាល | ជំងឺ??? | |

**បញ្ហាជារួម:**

- ចៃសស៊ុស្លឹក ស្លឹករញ៉ូម ចៃសស៊ីស្លឹក ត្រួយរួញ ទងរលួយ ផ្លែក្រិន និងស្អុយ ស្រាំងចុច ក្រាស៊ុ
- ព្រូន រាកស ប្រកាច់ ទន់ជើងដៃ អាច់ក្បៀន គ្រុនក្តៅ សារទឹក អុតក្តាម
- ប្រើថ្នាំគីមី

**អនុសាសន៍ក្រុមបច្ចេកទេស**

- ប្រើប្រាស់ថ្នាំបណ្តេញសត្វល្អិតធ្វើពីធម្មជាតិ បូកនិងសាប៊ូ និងប្រេងកាត (លំអិតនៅពេលបើកវគ្គបណ្តុះបណ្តាល)
- បន្ថយជី ឬកាត់ចុងដៃល្ពៅចោល (ករណីរលួយគល់)
- ថែមជី ថែទាំ (ករណីរួញដៃ)
- គ្រប់រលួយផ្លែ (គ្រប់ចេញផ្កាហើយត្រូវកាត់ស្លឹកចោល៣០% ,ករណីខ្លះប្រើជីខុស ដូច្នេះត្រូវមើលថែទាំទឹក ជី និងដី)
- ចៃរុំដើម: ប្រើសាប៊ូម្សៅលាយទឹកបាញ់ ឬយកផេះបាចលើវា
- មាន់: ថែទាំទឹក ចំណី ឧស្សាធ្វើអនាម័យទ្រុងមានជាប្រចាំ (មាន់មិនអាចព្យាបាលបានទេ តែការពារបាន) បើរោគដង្កោកាច់ត្រូវប្រើថ្នាំពេទ្យ (វ៉ាក់សាំងការពារជម្ងឺ)

– ចោកក្រាស៊ីៈ ប្រើអង្កាមដុត និងផេះដាក់ក្នុងអន្លង់ ឬគល់ចោក

**រោគសញ្ញា និងឈ្មោះជំងឺដែលគួរយល់ដឹងចំពោះសត្វ ហើយត្រៀមសំរាប់សំរន្ធរចូលរួមវគ្គបណ្តុះបណ្តាល(សុខ រឿន)**

| ជំងឺមាន់ | ជម្ងឺជ្រូក | ជម្ងឺគោ |
|---|---|---|
| – អាសន្នរោគ | – ប៉េស្ត | – សារទឹក |
| – ដង្កោកាច់ | – អាសន្នរោគ | – ឈាមខ្មៅ |
| – អុត | – អូយ៉ាស្គី | – អុតក្តាម |
| – ញាកាស | – កញ្ជិល | – បូសខ្យល់ |

ក្រោយបទបង្ហាញ អ្នកសំរបសំរួលបានពន្យល់ផ្តោតសំខាន់ពីរបៀបធ្វើផែនការ ដោយយកផែនទីក្តីស្រម៉ៃជាគោលៈ

តារាងផែនការរយៈពេល៥ខែក្រោយ (សីហា–ធ្នូ ២០១១)

| ល.រ | សកម្មភាព | ដំណើរការលំអិត | ពេលវេលា | ទីកន្លែង | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|
| | | | | | |

ធ្វើថ្ងៃទី... ខែ.... ឆ្នាំ២០...

រៀបចំដោយ......

ថ្ងៃទី... ខែ.... ឆ្នាំ២០...

បានឃើញ និងឯកភាព

បន្ទាប់ពីបានធ្វើផែនការ និងបង្ហាញរួចរាល់ អង្គសិក្ខាសាលាបានបូកសរុបលទ្ធផលដូចខាងក្រោមៈ

**លទ្ធផលសំរេចបានពីសិក្ខាសាលា**

១ ការចូលរួមបានគ្រប់ចំនួនដែលបានគ្រោងទុកមានចំនួន៥ខេត្ត (កំពង់ស្ពឺ, ក្រចេះ, បាត់ដំបង, ព្រះវិហារ និងកំពត) សរុបមាន អ្នកចូលរួម៣០នាក់ស្រី០៩នាក់ក្នុងនោះមានៈ

- អ្នកសំរបសំរួលចំនួន០៥នាក់ ស្រី០១នាក់
- បុគ្គលិកដឹកនាំកសិករចំនួន០៥នាក់
- កសិករគំរូ៥ខេត្តសរុប២០នាក់ ស្រី០៨នាក់

២ អ្នកចូលរួមបានយល់ដឹងពីគោលបំណងនៃការបង្កើត និងលក្ខណៈវិនិច្ឆ័យកសិករគំរូ និងយល់ដឹងពីការប្រើដី និងមានការសហការគ្នា ចែករំលែកបទពិសោធន៍ និងចំណេះដឹង ជាពិសេសចូលរួមយ៉ាងផុសផុលក្នុងសកម្មភាពសិក្ខាសាលារយៈពេល២ថ្ងៃនេះ

៣ កសិករយើងទទួលបានផែនទីបច្ចុប្បន្ន និងផែនទីក្តីស្រម៉ៃបានគ្រប់គ្នា

៤ កសិករទទួលបានផែនការសកម្មភាពសំរាប់ទៅអនុវត្តគ្រប់គ្នា ។

ជាចុងក្រោយលោកប្រធានបណ្ដាញ បានថ្លែងមតិសំណេះសំណាល និងបិទកម្មវិធីដូចខាងក្រោម:

ខ្ញុំសូមកោតសរសើរចំពោះ ការចូលរួមយ៉ាងសកម្មក្នុងសកម្មភាពបង្កើតក្រុមកសិករគំរូទី៣ នេះ ទោះជាធ្វើដំណើរឆ្ងាយលំបាកយ៉ាងណាក៏ដោយ កសិករយើងនៅមានកំលាំងចិត្តយ៉ាងស្វាហាប់ជានិច្ច ។ម្យ៉ាងទៀត ទោះបីការស្នាក់នៅ មិនមែនជាសណ្ឋាគារក៏ដោយ យើងទាំងអស់គ្នាមានចិត្តសប្បាយ ហើយក្នុងនេះដែរ ខ្ញុំមិនភ្លេចអរគុណចំពោះអង្គការ មជ្ឈមណ្ឌលម្លប់ព្រហ្មវិហារធម៌ ដែលបានទទួល និងជួយជ្រោមជ្រែងក្នុងដំណើរការសិក្ខាសាលាបង្កើតកសិករគំរូក្រុមទី ៣ នេះ ។

ជាចុងក្រោយខ្ញុំតំណាងក្រុមសំរបសំរួល សូមជូនពរដល់អស់លោក លោកស្រីជួបប្រទះតែពុទ្ធ៥ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លាឡើយ ។

សិក្ខាសាលានេះត្រូវបានបញ្ចប់នៅវេលាម៉ោង៥និង៣0នាទី ថ្ងៃទី0៣ សីហា ឆ្នាំ២០១១ ដោយរីករាយនិងទទួលខុសត្រូវខ្ពស់។

អ្នកសរសេរកំណត់ហេតុ



បានឃើញ និងឯកភាព

ប្រធានបណ្ដាញ

